# បោះឆ្នោតមុនពេលកំណត់ដោយសន្លឹកឆ្នោត សម្រាប់ពលរដ្ឋអវត្តមាន

VOTE 2016

នៅរដ្ឋMinnesotaអ្នកពុំចាំបាច់រង់ចាំទាល់តែដល់ថ្ងៃបោះឆ្នោតឡើយ–បោះឆ្នោតមុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន!

## បោះឆ្នោតមុនពេលកំណត់ដោយផ្ទាល់

អ្នកអាចបោះឆ្នោតជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាននៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកនៅក្នុងរយៈពេល 46 ថ្ងៃមុនថ្ងៃបោះឆ្នោត។សូមចូលទៅកាន់វេបសាយត៍ mnvotes.org ដើម្បីទទួលព័ត៌មានអំពីពេលវេលានិងទីតាំង។

## បោះឆ្នោតមុនពេលកំណត់តាមសំបុត្រ

អ្នកក៏អាចដាក់ពាក្យស្នើសុំឱ្យបញ្ជូនសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានតាមលិខិតផងដែរ។អ្នកត្រូវប្រគល់សន្លឹកឆ្នោតរបស់អ្នកនៅត្រឹមថ្ងៃបោះឆ្នោត។

① ដាក់ពាក្យស្នើសុំសន្លឹកឆ្នោតនៅពេលណាមួយនៅក្នុងឆ្នាំតាមវេបសាយត៍mnvotes.org។មន្ត្រីបោះឆ្នោតនឹងផ្ញើឯកសារបោះឆ្នោតនៅពេលមានសន្លឹកឆ្នោត (សូមមើលទំព័រក្រោយសម្រាប់កាលបរិច្ឆេទ)។

② សូមអានសេចក្តីណែនាំដែលភ្ជាប់ជាមួយសន្លឹកឆ្នោតរបស់អ្នកដោយយកចិត្តទុកដាក់! សន្លឹកឆ្នោតរបស់អ្នកនឹងក្លាយជាសន្លឹកឆ្នោតអត់បានការប្រសិនបើអ្នកមិនបំពេញគ្រប់ទម្រង់បែបបទទេ។

### កាលបរិច្ឆេទឆ្នាំ 2016

**ការបោះឆ្នោតបឋម**
ថ្ងៃអង្គារ៍ទី09 ខែសីហា

**ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន**
បោះឆ្នោតតាមសំបុត្រ ឬដោយផ្ទាល់ថ្ងៃទី23 ខែកញ្ញា រហូតដល់ថ្ងៃទី7 ខែវិច្ឆិកា

**ចុះឈ្មោះបោះឆ្នោត**
ចុះឈ្មោះជាមុននៅត្រឹមថ្ងៃទី18 ខែតុលា ដើម្បីសន្សំសំចៃពេលវេលានៅថ្ងៃបោះឆ្នោត។

**ថ្ងៃបោះឆ្នោត**
ថ្ងៃអង្គារ៍ទី8 ខែវិច្ឆិកា

③ អ្នកនឹងត្រូវការសាក្សីនៅពេលអ្នកបោះឆ្នោតនិងបំពេញសន្លឹកឆ្នោតរបស់អ្នក។សាក្សីអាចជាអ្នកបោះឆ្នោតនៅរដ្ឋMinnesotaដែលបានចុះឈ្មោះត្រឹមត្រូវឬជាសាការី។សាក្សីរបស់អ្នកត្រូវចុះហត្ថលេខានៅលើស្រោមសំបុត្រហត្ថលេខានិងដាក់អាស័យដ្ឋានរបស់គាត់។

④ ប្រសិនបើអ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតទេ អ្នកនឹងទទួលបានពាក្យស្នើសុំចុះឈ្មោះ

តទៅទំព័រក្រោយ...

ការិយាល័យលេខាធិការរដ្ឋMinnesota
mnvotes.org • 1-877-600-VOTE

# បោះឆ្នោតមុនពេលកំណត់ដោយសន្លឹកឆ្នោត សម្រាប់ពលរដ្ឋអវត្តមាន

**VOTE 2016**

*...តពីទំព័រមុខ*

បោះឆ្នោតនៅក្នុងឯកសាររបស់អ្នក។ ដើម្បីចុះឈ្មោះសូមបង្ហាញ សាក្សីរបស់អ្នកនូវឯកសារបញ្ជាក់អត្តសញ្ញាណណាមួយដែលមានរៀបរាប់នៅក្នុងសេចក្តីណែនាំ។ សាក្សី របស់អ្នកត្រូវគូសឯកសារបញ្ជាក់អត្តសញ្ញាណមួយដែលអ្នកបានបង្ហាញពួកគាត់នៅលើស្រោមសំបុត្រហត្ថលេខា។

⑤ បន្ទាប់ពីអ្នកបញ្ចប់សូមផ្ញើសន្លឹកឆ្នោតនិងទម្រង់ត្រឡប់ទៅវិញភ្លាមៗ។សន្លឹកឆ្នោតរបស់អ្នកនឹងទុកជាអត់បានការប្រសិនបើត្រូវបានទទួលនៅបន្ទាប់ពីថ្ងៃបោះឆ្នោត។អ្នកក៏អាចប្រគល់សន្លឹកឆ្នោតដោយផ្ទាល់ដល់ការិយាល័យបោះឆ្នោតដែលបានផ្ញើសន្លឹកឆ្នោតទៅឱ្យអ្នក។

## *តាមដានសន្លឹកឆ្នោតរបស់អ្នក*

រាល់សន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានទាំងអស់ដែលបានទទួលទាន់ពេលវេលានិងបានបំពេញទម្រង់បែបបទត្រឹមត្រូវនឹងត្រូវរាប់ជាសន្លឹកឆ្នោតបានការ។សូមចូលមើលវេបសាយត៍ mnvotes.org ដើម្បីតាមដានស្ថានភាពសន្លឹកឆ្នោតរបស់អ្នកនិងបញ្ជាក់ថាសន្លឹកឆ្នោតនោះបានទទួលនិងរាប់ជាសន្លឹកឆ្នោតបានការ។

| *កាលបរិច្ឆេទឆ្នាំ2016* | ការបោះឆ្នោតបឋម | ការបោះឆ្នោតសកល |
|---|---|---|
| សន្លឹកឆ្នោតដែលបានបញ្ជូនកំពុងចាប់ផ្តើម | ថ្ងៃសុក្រទី24 ខែមិថុនា | ថ្ងៃសុក្រទី23 ខែកញ្ញា |
| ដែលបានណែនាំឱ្យអ្នកដាក់ពាក្យស្នើសុំពីមុន | ថ្ងៃសុកទី8 ខែកក្កដា | ថ្ងៃសុក្រទី7 ខែកញ្ញា |
| ថ្ងៃខែផុតកំណត់សម្រាប់ទទួលសន្លឹកឆ្នោត | ថ្ងៃបោះឆ្នោត ថ្ងៃអង្គារទី9 ខែសីហា | ថ្ងៃបោះឆ្នោត ថ្ងៃអង្គារទី8 ខែវិច្ឆិកា |

*ការិយាល័យលេខាធិការរដ្ឋMinnesota*
*mnvotes.org • 1-877-600-VOTE*

ខែមីនាឆ្នាំ2016